Government of South Australia

# ធម្មនុញ្ញពហុវប្បធម៌ រដ្ឋអូស្ត្រាលីខាងត្បូង

*ច្បាប់ពហុវប្បធម៌ រដ្ឋអូស្ត្រាលីខាងត្បូង ឆ្នាំ 2021* ចែងពីការធ្វើឱ្យរីកចម្រើនខាងពហុវប្បធម៌និយម និងអន្តរវប្បធម៌និយម ហើយផ្តល់សម្រាប់ធម្មនុញ្ញពហុវប្បធម៌រដ្ឋអូស្ត្រាលីខាងត្បូង (ធម្មនុញ្ញ)។ ធម្មនុញ្ញនេះនឹងផ្តល់ចក្ខុវិស័យ និងការណែនាំដល់ទីភ្នាក់ងារ អង្គការ ស្ថាប័ន អាជីវកម្ម និងសហគមន៍នានាក្នុងរដ្ឋក្នុងរដ្ឋអូស្ត្រាលីខាងត្បូង ថាជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍គោលនយោបាយរដ្ឋអូស្ត្រាលីខាងត្បូងទាំងអស់ និងការរចនាហើយនិងការផ្តល់ជូនសេវាកម្មរបស់ពួកគេ។

### ធម្មនុញ្ញពហុវប្បធម៌រដ្ឋអូស្ត្រាលីខាងត្បូង ទទួលស្គាល់៖

- ជនជាតិដើមថាជាម្ចាស់ប្រពៃណី និងអ្នកកាន់កាប់ដី និងទឹកនៅរដ្ឋអូស្ត្រាលីខាងត្បូង ដែលបន្តរក្សា និងអភិវឌ្ឍជំនឿវប្បធម៌ និងបេតិកភណ្ឌរបស់ពួកគេ ថាជាវប្បធម៌ចម្រុះដែលរស់នៅបានយូរបំផុត ដោយមានតួនាទីជាប្រវត្តិសាស្ត្រ និងជាបន្តដ៏សំខាន់ ក្នុងនាមជាប្រជាជននៃប្រជាជាតិទីមួយនៅរដ្ឋអូស្ត្រាលីខាងត្បូង។
- សមិទ្ធិផល និងបញ្ហាប្រឈមរបស់មនុស្សជំនាន់មុនៗ ដែលមកមុនយើង រួមជាមួយនឹងសហគមន៍ថ្មីៗ និងដែលកំពុងលេចឡើង និងអស់អ្នកដែលជួយរៀបចំអត្តសញ្ញាណរដ្ឋអូស្ត្រាលីខាងត្បូង។

### ធម្មនុញ្ញនេះគឺសម្រាប់ពលរដ្ឋអូស្ត្រាលីខាងត្បូងទាំងអស់ ហើយស្វែងរក ដើម្បី៖

- ភ្ជាប់សហគមន៍របស់យើងតាមរយៈការទទួលស្គាល់ភាពចម្រុះនៃវប្បធម៌ ភាសា ជាតិសាសន៍ និងសាសនា។
- បង្កើតបរិយាកាសមួយដើម្បីបញ្ចេញ ផ្លាស់ប្តូរចំណេះដឹង គំនិត និងទស្សនៈយ៉ាងសកម្ម ដើម្បីឱ្យពលរដ្ឋអូស្ត្រាលីខាងត្បូងទាំងអស់បង្កើតការយល់ដឹង និងការគោរពកាន់តែស៊ីជម្រៅចំពោះភាពសម្បូរ បែប និងគុណតម្លៃនៃភាពចម្រុះរបស់យើង។
- ផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍គោលនយោបាយពហុវប្បធម៌ និងការផ្តល់សេវាកម្មនានា ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់សហគមន៍របស់យើង និងនាំទៅរកការរីកចម្រើននៃរដ្ឋរបស់យើង។
- លើកទឹកចិត្តដល់កន្លែងធ្វើការ និងសហគមន៍នានាដែលមានលក្ខណៈរួមបញ្ចូល ហើយដែលទទួលខុសត្រូវសម្រាប់ពលរដ្ឋអូស្ត្រាលីខាងត្បូងទាំងអស់។

## គោលការណ៍ ធម្មនុញ្ញ

### ធម្មនុញ្ញពហុវប្បធម៌រដ្ឋអូស្ត្រាលីខាងត្បូង ចែងពីគោលការណ៍នានា ដែលពលរដ្ឋអូស្ត្រាលីខាងត្បូងទាំងអស់៖

1. ទទួលស្គាល់ គោរព និងឱ្យតម្លៃលើភាពចម្រុះនៃវប្បធម៌ ភាសា ជាតិសាសន៍ និងសាសនា ហើយនិងការរួមចំណែកដែលបានធ្វើ និងបន្តធ្វើដល់រដ្ឋរបស់យើង។
2. ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការផ្លាស់ប្តូរចំណេះដឹង និងការយល់ដឹងទៅវិញទៅមកអំពីភាពចម្រុះនៃវប្បធម៌ ភាសា ជាតិសាសន៍ និងសាសនារបស់យើង។
3. អាចរស់នៅ ធ្វើការ និងសិក្សា ដើម្បីរីកចម្រើនលើគ្រប់វិស័យនៃជីវិត ក្នុងសង្គមដ៏រួបរួមគ្នាមួយ។
4. មានសិទ្ធិក្នុងការគោរពគ្នាទៅវិញទៅមក ការយល់ដឹង យុត្តិធម៌ សុវត្ថិភាព និងសេរីភាពពីការរើសអើងដោយផ្អែកលើមូលដ្ឋានវប្បធម៌ ភាសា ពូជសាសន៍ និងសាសនារបស់ពួកគេ។
5. គួរតែអាចរក្សាទុក បញ្ចេញ អនុវត្ត និងអបអរសាទរភាពចម្រុះនៃវប្បធម៌ ភាសា និងសាសនារបស់ពួកគេ។
6. មានសិទ្ធិទទួលបានភាពសមធម៌ក្នុងឱកាស និងសេវាកម្មនានាដែលគាំទ្រដល់ការចូលរួមក្នុងជីវិតអប់រំ សង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយនៃរដ្ឋរបស់យើង។

Honourable Peter Malinauskas MP
Premier of South Australia

Honourable Zoe Bettison MP
Minister for Multicultural Affairs

Damien Walker
Chief Executive
Department of the Premier and Cabinet

គណៈកម្មការពហុវប្បធម៌រដ្ឋអូស្ត្រាលីខាងត្បូងត្រូវបានទទួលស្គាល់ចំពោះការរួមចំណែករបស់ខ្លួន ក្នុងការអភិវឌ្ឍន៍ធម្មនុញ្ញពហុវប្បធម៌អូស្ត្រាលីរដ្ឋខាងត្បូង។ 